សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (ស.ទ.ក)
Cambodian Water Supply Association (C.W.A)

# សេចក្តីជូនដំណឹង
# ស្តីពី
# ការជ្រើសរើសក្រុមហ៊ុន ខួងអណ្តូងទឹកស្អាត

សមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា (CWA) អង្គការយូនីសេហ្វ (UNICEF) និងប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតសេកគង់ ប្រតិបត្តិករផ្គត់ផ្គង់ទឹកស្អាតប៉េងហុង ស្ថិតនៅក្នុងស្រុកឧដុង្គ ខេត្តកំពង់ស្ពឺ បាននឹងកំពុងអនុវត្តគម្រោង **«បង្កើននូវភាពធន សម្រាប់ការផ្គត់ផ្គង់ទឹកស្អាតដល់ប្រជាជនរស់នៅក្នុងតំបន់ដែលបានរងគ្រោះពីគ្រោះធម្មជាតិ ដែលមិនទាន់មានបណ្តាញទឹកស្អាត»** ក្រោមជំនួយថវិកាពីអង្គការយូនីសេហ្វ ក្នុងក្របខណ្ឌកិច្ចសហប្រតិបត្តិការជាមួយក្រសួងឧស្សាហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍។ សមាគមមានកិត្តិយសសូមអញ្ជើញក្រុមហ៊ុន ឬអ្នកម៉ៅការ ដែលមានបទពិសោធន៍ក្នុងការខួងអណ្តូងទឹកស្អាត និងបំពាក់បរិក្ខារអណ្តូង ព្រមទាំងបូមទឹកវាស់ជាទឹកអណ្តូង (Pumping Test) ជូនដល់ប្រតិបត្តិករទឹកស្អាតទាំងពីរដូចមានក្នុងតារាងព័ត៌មាន និងលក្ខខណ្ឌលម្អិតដូចខាងក្រោម៖

| ល.រ | តំបន់គោលដៅ | ចំនួនអណ្តូង |
|---|---|---|
| ១ | ឃុំក្សេមក្សាន្ត ស្រុកឧត្តុដុង ខេត្តកំពង់ស្ពឺ | 3 |
| ២ | ឃុំចាន់សែន ស្រុកឧត្តុដុង ខេត្តកំពង់ស្ពឺ | 4 |
| ៣ | បរិមាណទឹកអណ្តូងខួង= 2 m3/h ទៅ3m3/h(កំលាំងសេស5ph-10hp) | |
| ៤ | បូមវាស់ជាទឹកអណ្តូង 30ម៉ោង/អណ្តូង ពេលខួងរួចរាល់ | |

1. រាល់ឯកសារដេញថ្លៃរួមមាន៖ ពាក្យសុំដេញថ្លៃ និងឯកសារភ្ជាប់នានា ត្រូវដាក់ក្នុងស្រោមសំបុត្របិទជិត រួចផ្ញើមកការិយាល័យសមាគម រៀងរាល់ម៉ោងធ្វើការឱ្យបានមុនថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ២០២១។ រាល់ឯកសារដេញថ្លៃទាំងឡាយដែលបានដាក់ក្រោយកាលបរិច្ឆេទ មិនត្រូវបានពិចារណាឡើយ។
2. ក្រុមហ៊ុនដែលមានចំណាប់អារម្មណ៍ អាចមកទទួលឯកសារដេញថ្លៃនៅសមាគមអ្នកផ្គត់ផ្គង់ទឹកស្អាតកម្ពុជា ដោយឥតគិតថ្លៃ ដែលមានអាសយដ្ឋានដូចរៀបរាប់ខាងក្រោម ឬទាញយកពីគេហទំព័រ www.cwa.org.kh ឬទំព័រហ្វេសប៊ុក Cambodian Water Supply Association និង អ៊ីមែល៖ info@cwa.org.kh។ ***រាល់តម្លៃត្រូវបូកបញ្ចូលពន្ធលើតម្លៃបន្ថែម(VAT) ឬបញ្ជាក់ពីការបង់ពន្ធកាត់ទុក (Withholding Tax) ក្នុងករណីពុំមាន(VAT)។***
3. ការបើកស្រោមសំបុត្រដេញថ្លៃនឹងត្រូវប្រព្រឹត្តឡើងជាសាធារណៈនៅការិយាល័យសមាគម នា**ថ្ងៃទី១៦ ខែវិច្ឆិកា ឆ្នាំ២០២១ វេលាម៉ោង ២:០០រសៀល** ដែលមានអ្នកចូលរួមមកពីតំណាងស្ថានីយផ្គត់ផ្គង់ទឹកស្អាត តំណាង អង្គការយូនីសេហ្វ តំណាងមកពីក្រសួងឧសហកម្ម វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ និងតំណាងក្រុមហ៊ុនដាក់ដេញថ្លៃ។
4. **អាសយដ្ឋានទំនាក់ទំនង និងដាក់ពាក្យ៖** មជ្ឈមណ្ឌលភ្នំពេញ អគារF ជាន់ទី២ វិថីសម្តេចសុធារស សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញឬ ទូរស័ព្ទលេខ៖ ០១២ ៩៩៤ ៧៦០ ឬ ០១៧ ៧៩៩ ៣៣៧ ឬ ០៧០ ៧៩៩ ៣៣៧ ឬ ០៩៧៧ ១៧៩ ៩៤៣។ អ៊ីមែល៖ info@cwa.org.kh គេហទំព័រ៖ www.cwa.org.kh